# បំណែកផូស៊ីលធ្មេញនៅភ្នំគូលែន

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ មានផ្ទៃដីសរុបចំនួន ៣៧៩០០ហិចតា និងមានតួនាទីសំខាន់សម្រាប់ការរក្សាលំនឹងបរិស្ថាននៅតំបន់អង្គរ ដោយសារប្រភពធនធានដ៏សម្បូរបែប ដូចជា ព្រៃឈើ ប្រភពទឹក និងធនធានជីវៈចម្រុះ ។ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារនៃនាយកដ្ឋានតំបន់បេតិកភណ្ឌ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន ដោយមានការចូលរួមពីមន្ត្រីឧទ្យានុរក្សនៃឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» អ្នកបច្ចេកទេស និងអ្នកស្ម័គ្រចិត្ត បានចុះសិក្សាពិនិត្យតំបន់ដែលមានផូស៊ីលដើមឈើដែលបានរកឃើញកាលពីលើកមុន និងបានចុះផ្សាយក្នុងគេហទំព័រ AMS អរិយធម៌ខ្មែរ រួចម្តងមកហើយ ស្តីអំពីការរកឃើញផូស៊ីលដើមឈើថ្មនៅភ្នំគូលែន។ ដោយពេលថ្មីៗនេះ ក្រុមការងារបានចុះសិក្សានៅតំបន់នោះម្តងទៀតដែលឆ្ងាយពីទីផូស៊ីលដើមឈើថ្មប្រមាណ២គីឡូម៉ែត្រ ក៏បានប្រទះឃើញនៅផូស៊ីលបំណែកធ្មេញតូចមួយ និងបំណែកនៃផូស៊ីលឈើកប់ក្នុងស្រទាប់ថ្ម Conglomerate (ថ្មក្តាំង?)។ ហេតុអ្វីយើងគួរបង្ហាញអំពីពត៌មាននេះ?

លក្ខណៈនៃភូគព្ភសាស្ត្រនៃតំបន់ភ្នំគូលែន ជាប្រភេទភ្នំថ្មភក់មានបណ្តោយ៥០គីឡូម៉ែត្រ និងទទឹង១៨គីឡូម៉ែត្រ។ កន្លែងដែលបានចុះសិក្សាស្ថិតនៅភាគខាងកើតភ្នំគូលែន (រូបលេខ១) ក្នុងភូមិសាស្ត្រ ភូមិទឹកលិច ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប។ ភ្នំគូលែនជាប្រភេទភ្នំថ្មភក់ ដែលតាមរយៈផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា កំណត់សំគាល់ដោយអក្សរ J1 K1ss ដែលស្ថិតនៅស័កទី២ ( Mesozoic Era ) ក្នុងសម័យកាលជូរ៉ាស៊ីក និងសម័យគ្រេតាស៊ីស (Jurassic and Cretaceous )[១] មានអាយុកាលចន្លោះ ៦៥,៦ ទៅ ១៩៩,៦លានឆ្នាំ នេះចំពោះតែអាយុថ្មនៃភ្នំគូលែន។ បំណែកផូស៊ីលនេះ ត្រូវបានរកឃើញនៅចង្កេះភ្នំ ត្រង់ចំនុច ដាស្រី ដែលមាននិយាមកា X-411760 Y-1491898 និងមានកម្ពស់ប្រមាណ១០០ម៉ែត្រធៀបនឹងទឹកសមុទ្រ។ ធ្មេញនោះបានកប់នៅក្នុង ប្រភេទថ្មមួយហៅថា Conglomerate (ថ្មក្តាំង?) ដែលជាប្រភេទសិលាចាក់បង្គរ ដែលផ្សំឡើងដោយគ្រួស

[១] General Department of Mineral Resource, 2010, Geological Map of Cambodia

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

អាចម៍ផ្កាយរាងមូលដែលមានអង្កត់ផ្ចិតធំជាងពីរមីលីម៉ែត្រ (រូបលេខ២-៣) ចន្លោះនៃគ្រួសអាចម៍ផ្កាយជាទូទៅត្រូវបានបំពេញដោយភាគល្អិតដែលមានទំហំខ្សាច់ និងដីឥដ្ឋ ហើយត្រូវបានភ្ជាប់គ្នាដោយសារជាតុកាល់ស៊ីត និងក្វាត។[២] ថ្ម Conglomerate កើតឡើងដោយការចាក់បង្គរ ដោយល្បាប់ និងគ្រួស ឬថ្មតូចៗ។ គ្រួសឬថ្មដែលមាននៅក្នុងថ្មនេះមានទំហំតូចៗមានន័យថាចរន្តទឹកក្នុងពេលនោះ ហូរមិនសូវខ្លាំង។ ប្រសិនបើមានគ្រួសអាចម៍ផ្កាយ ឬថ្មក្នុងនោះមានទំហំធំ មានន័យថាការកកើតនៅកន្លែងនោះមានចរន្តទឹកហូរខ្លាំង។ ឧទាហរណ៍នៅតំបន់រាមសារ ក្នុងស្រុកបូរីអូរស្វាយ ខេត្តស្ទឹងត្រែង នៅតាមកោះមួយចំនួនដែលស្ថិតនៅក្នុងទន្លេមេគង្គ ខ្ញុំបានជួបប្រទះគ្រួសអាចផ្កាយមានទំហំធំៗ ជាច្រើន ដែលបានហូរមកចាក់បង្គរនៅចំពីមុខកោះ ដែលមានទឹកហូរខ្លាំង និងគ្រួសតូចៗបានហូរចាក់ទៅទីតាំងដែលមានទឹកមិនសូវហូរខ្លាំង ចំណែកខ្សាច់ក៏ចាក់នៅផ្នែកណាដែលទឹកហូរខ្សោយ ឬបាំងមុខទឹកដោយរុក្ខជាតិ ឬកោះ។ នៅតំបន់ថ្មអណ្តូងជាទីតាំងយកថ្មបុរាណ យើងបានជួបប្រទះប្រភេទថ្ម Conglomerate នៅស្រទាប់ផ្នែកខាងលើថ្មដែលគេកាត់យកទៅធ្វើប្រាសាទជាថ្មភក់មានពណ៌ប្រផេះពណ៌បៃតង។ ចំណែកនៅផ្នែកខាងលើនៃថ្មភក់នេះមានទីតាំងខ្លះយើងបានជួបពពួកថ្ម Conglomerate ដោយកន្លែងនោះមានទៅតាមស្រទាប់នៃផ្នែកខាងលើខ្លះៗរបស់ថ្មភក់។ តាមទីតាំងមួយចំនួនយើងបានជួបពពួកថ្មភក់ពណ៌រាងក្រហមដែលមានសណ្ឋានជាពើងនៅផ្នែកខាងលើនៃថ្មភក់ដែលបានយកទៅសាងសង់ប្រាសាទផងដែរ។

បំណែកឆ្អឹងដែលកប់ក្នុងថ្ម Conglomerate នៅតំបន់ដាស្រី ស្ថិតក្នុងបរិវេណថ្មប្រមាណ ២០ម៉ែត្រ និងកម្រាស់២០ទៅ៣០ស.ម។ បំណែកឆ្អឹងនោះមានទំហំតូច ប្រវែង៣ស.ម ប៉ុណ្ណោះ (រូបលេខ៤-៥)។ ឆ្អឹងនេះមានកម្រាស់ស្តើង មានផ្នែករលោងសងខាងអាចជាបំណែកឆ្អឹងស្មាបប្រចៀវ ឬឆ្អឹងផាលត្រកៀក នៃសត្វណាមួយក្នុងសម័យបុរាណ។ ឆ្អឹងនេះបានហូរទៅតាមទឹក ក្រោយមកកកជាមួយកំទេចថ្ម និងល្បាប់ ហើយក្រោយមកក៏ក្លាយជាថ្ម។ ក្រៅពីបំណែកផូស៊ីលឆ្អឹង នៅក្បែរនោះក៏មានបំណែកផូស៊ីលឈើ ដែលកកទៅជាថ្មផងដែរ។ បំណែកផូស៊ីលឈើកប់ក្នុងថ្មដែលមានប្រវែងប្រមាណ១០ស.ម (រូបលេខ៦)។ បំណែក

[២] https://en.wikipedia.org/wiki/Conglomerate_(geology)

ឈើនោះក៏បានក្លាយទៅជាថ្មហើយផងដែរ។ តាមរយៈផែនទី ភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា នៅតំបន់ភ្នំគូលែននេះក៏បាននិយាយពីថ្ម Conglomerate នេះផងដែរ ដែលមានអាយុកាល ស្ថិតនៅស័កទី២ ( Mesozoic Era ) ក្នុងសម័យកាល ជូរ៉ាស៊ីក និងសម័យគ្រេតាស៊ីស (Jurassic and Cretaceous )[៣] ដែលមានអាយុកាលចន្លោះ ៦៥,៦ ទៅ១៩៩,៦លានឆ្នាំ។ បំណែកឆ្អឹងតូចនេះជាទិន្នន័យថ្មីមួយសម្រាប់ការសិក្សាស្រាវជ្រាវបន្ត អំពីជីវិតសត្វ និងរុក្ខជាតិនាសម័យនោះផងដែរ។ វាក៏ជាការបង្ហាញអំពីបាតុភូតនៃធម្មជាតិ ដែលអាចធ្វើឱ្យយើងស្វែងយល់ពីបាតុភូតដែលកើតឡើងនៅតំបន់ភ្នំគូលែនផងដែរ។




រូបលេខ១ ចំនុចទីតាំងផូស៊ីលឆ្អឹង នៅខាងកើតភ្នំគូលែន

[៣] General Department of Mineral Resource, 2010, Geological Map of Cambodia

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១២ ថ្ម Conglomerate ឬថ្មក្តាំង?



រូបលេខ១៣ ថ្ម Conglomerate ឬថ្មក្តាំង?

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ២៤ បំណែកផូស៊ីលឆ្អឹងកកក្នុងថ្ម



រូបលេខ២៥ បំណែកផូស៊ីលឆ្អឹងកកក្នុងថ្ម

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ២៦បំណែកផូស៊ីលឈើ



រូបលេខ២៧ ក្រុមការងារពេលចុះសិក្សា

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ